ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception):
07 / 09 / 2016
ម៉ោង (Time/Heure): 14:35
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

សាធារណៈ / Public

# អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០១៦

**ជូនចំពោះ៖** ភាគីទាំងអស់នៃសំណុំរឿង ០០២

**ពី៖** ចៅក្រម យ៉ា សុខន ជ.ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន៖** លោក/លោកស្រីចៅក្រម និង មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ៖** សេចក្តីសម្រេចលើសំណើរបស់ នួន ជា អនុលោមតាមវិធាន ៨៧(៤) សុំឱ្យទទួលយកជាភស្តុតាងនូវឯកសារមួយពាក់ព័ន្ធនឹងសក្ខីកម្មរបស់អ្នកជំនាញ Henri LOCARD (2-TCE-90)

TRIAL CHAMBER * CHAMBRE DE PREMIÈRE INSTANCE * E.C.C.C * C.E.T.C *

១. អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណើមួយ អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ដែលបានដាក់នៅថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០១៦ ដោយមេធាវីការពារក្តី នួន ជា សុំឱ្យទទួលយកជាភស្តុតាងនូវឯកសារមួយដែលពាក់ព័ន្ធនឹងសក្ខីកម្មរបស់អ្នកជំនាញ Henri LOCARD (2-TCE-90) (“សំណើ” ឯកសារ E415/3 កថាខណ្ឌ ១, ១០)។ ឯកសារនោះគឺជាអត្ថបទសារព័ត៌មានមួយដែលមានចំណងជើងថា “ប្រវត្តិវិទូជនជាតិបារាំងចោទប្រកាន់មេធាវីការពារក្តីនៅសាលាក្តីអំពី“ទារុណកម្មត្រជាក់”” ដែលបានចុះផ្សាយនៅក្នុងសារព័ត៌មាន *ខេមបូឌាដេលី* (“ឯកសារ” ឯកសារ E415/3.1.1)។ មេធាវីការពារក្តីលើកឡើងថា សំណើនេះបានដាក់ទាន់ពេលវេលា ដោយសារអត្ថបទនេះបានចុះផ្សាយនៅថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០១៦ បន្ទាប់ពីលោក LOCARD (2-TCE-90) មកផ្តល់សក្ខីកម្មក្នុងសំណុំរឿង ០០២/០២

(ឯកសារ E415/3 កថាខណ្ឌ ៧)។ មេធាវីការពារក្តីលើកឡើងទៀតថា សារព័ត៌មាន*ខេមបូឌា ដេលី* គឺជា "សារព័ត៌មានកម្ពុជាដ៏ច្បាស់លាស់ និង អាចជឿជាក់បាន" ហើយថា ឯកសារនេះរាយការណ៍អំពីចម្លើយរបស់លោក LOCARD (2-TCE-90) ដែលពាក់ព័ន្ធទៅនឹងភាពមិនលម្អៀង និង ភាពគួរឱ្យទុកចិត្តបានរបស់គាត់ក្នុងនាមជាអ្នកជំនាញ (ឯកសារ E415/3 កថាខណ្ឌ ៥, ៨-៩)។

២. នៅថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១៦ សហព្រះរាជអាជ្ញាបានដាក់ចម្លើយតបទៅនឹងសំណើសុំ (ឯកសារ E415/3/1)។ ទោះបីសហព្រះរាជអាជ្ញាមិនយល់ស្របទៅនឹងសេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តី នួន ជា ទាក់ទិននឹងឯកសារនេះក៏ដោយ តែសហព្រះរាជអាជ្ញាមិនជំទាស់ទៅនឹងការទទួលយកឯកសារនេះធ្វើជាឯកសារភ័ស្តុតាងនោះឡើយ (ឯកសារ E415/3/1 កថាខណ្ឌ ២)។ សហព្រះរាជអាជ្ញាលើកឡើងថា ឯកសារនេះ មិនមានបង្ហាញពីគំនិតបុរេវិនិច្ឆ័យ ឬ ភាពលម្អៀងនៅក្នុងស្នាដៃសិក្សាស្រាវជ្រាវរបស់លោក LOCARD (2-TCE-90) ឬ សក្ខីកម្មរបស់គាត់ឡើយ ហើយថាគាត់បានបំពេញបទដ្ឋានតម្រូវនៃភាពអាចជឿជាក់បាន ក្នុងនាមជាអ្នកជំនាញ (ឯកសារ E415/3/1 កថាខណ្ឌ ៤-៥)។

៣. អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង នៅគ្រប់ដំណាក់កាលនៃនីតិវិធីទាំងអស់ អង្គជំនុំជម្រះអាចទទួលយកនូវភ័ស្តុតាងទាំងឡាយណាដែលអង្គជំនុំជម្រះយល់ឃើញថាមានប្រយោជន៍សម្រាប់នាំមកនូវការស្វែងរកការពិត ក្នុងករណីដែលភ័ស្តុតាងនោះបំពេញទៅតាមបទដ្ឋាន*បឋម* នៃភាពពាក់ព័ន្ធ ភាពអាចជឿជាក់បាន និង យថាភាព ដែលតម្រូវដោយវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង។ អង្គជំនុំជម្រះនឹងសម្រេចលើសំណើសុំឱ្យទទួលយកភ័ស្តុតាងថ្មី ស្របតាមលក្ខណៈវិនិច្ឆ័យដូចមានចែងនៅក្នុងវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង។ វិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ក៏តម្រូវផងដែរថា ភាគីដែលស្នើសុំឱ្យទទួលយកភ័ស្តុតាងថ្មី ត្រូវបញ្ជាក់មូលហេតុនៃការស្នើសុំនេះឱ្យបានច្បាស់លាស់។ ភាគីស្នើសុំត្រូវធ្វើឱ្យអង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា ភ័ស្តុតាងដែលខ្លួនបានស្នើសុំដាក់នោះ មិនអាចរកបាននៅមុនពេលចាប់ផ្តើមការជំនុំជម្រះ ឬ មិនអាចត្រូវបានរកឃើញ ទោះបីជាបានខិតខំព្យាយាមយ៉ាងសមស្របហើយក៏ដោយ។ ទោះបីជាយ៉ាងណាក៏ដោយ នៅក្នុងករណីមួយចំនួន អង្គជំនុំជម្រះបានទទួលយកភ័ស្តុតាងនានាដែលពុំបានបំពេញទៅតាមលក្ខណៈវិនិច្ឆ័យនេះឡើយ រួមទាំងក្នុង

ករណីដែលភ័ស្តុតាងពាក់ព័ន្ធយ៉ាងជិតស្និទ្ធជាមួយនឹងសម្ភារៈដែលមានរួចហើយនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង និង ក្នុងករណីដែលប្រយោជន៍នៃយុត្តិធម៌តម្រូវឱ្យមានការវាយតម្លៃប្រភពទាំងនេះរួមគ្នា និង ករណីដែលឯកសារដែលបានស្នើសុំដាក់នេះ គឺជាភ័ស្តុតាងដោះបន្ទុកដែលតម្រូវឱ្យមានការវាយតម្លៃដើម្បីជៀសវាងកំហុសក្នុងការស្វែងរកយុត្តិធម៌ (ឯកសារ E276/2 កថាខណ្ឌ ២ យោងទៅឯកសារ E190 និង E172/24/5/1, ឯកសារ E260 កថា-ខណ្ឌ ៥)។

៤. អង្គជំនុំជម្រះយល់ឃើញថា ឯកសារនេះមិនអាចរកបានមុនពេលចាប់ផ្តើមការជំនុំជម្រះ ហើយថា មេធាវីការពារក្តីបានបំពេញការងារយ៉ាងយកចិត្តទុកដាក់ ដោយបានដាក់សំណើក្នុងរយៈពេល ០៥ ថ្ងៃបន្ទាប់ពីអត្ថបទនោះត្រូវបានចុះផ្សាយ។ ហេតុនេះ សំណើនេះ បានដាក់ទាន់ពេលវេលា។ ឯកសារនេះត្រូវបានចុះផ្សាយនៅក្នុងសារព័ត៌មាន *ខេមបូឌា ដេលី* ហើយហេតុនេះ វាបំពេញទៅតាមបទដ្ឋាន*បឋម* នៃភាពជឿជាក់បាន និង យថាភាព ដែលតម្រូវនៅក្នុងវិធាន៨៧(៣) នៃវិធានផ្ទៃក្នុង។ អង្គជំនុំជម្រះយល់ឃើញថា ឯកសារនេះមានភាពពាក់ព័ន្ធនឹងព័ត៌មានទាក់ទិននឹងការផ្តល់សក្ខីកម្មរបស់លោក LOCARD (2-TCE-90) នៅចំពោះមុខ អ.វ.ត.ក។ ទាក់ទិននឹងការធ្វើសេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តីដែលថា ឯកសារបង្ហាញអំពី "ការមើលងាយយ៉ាងធ្ងន់ធ្ងរមកលើជនជាប់ចោទ និង មេធាវីការពារក្តីជាទូទៅ" របស់លោក LOCARD (2-TCE-90) (ឯកសារ E415/3 កថាខណ្ឌ ១) អង្គជំនុំជម្រះសូមរម្លឹកថា ការជំទាស់ទៅនឹងគំនិតបុរេវិនិច្ឆ័យរបស់អ្នកជំនាញ គឺពាក់ព័ន្ធនឹងតម្លៃនៃភ័ស្តុតាង មិនមែនពាក់ព័ន្ធជាមួយភាពអាចទទួលយកបាននៃភ័ស្តុតាងឡើយ (ឯកសារ E215 កថាខណ្ឌ ១៥)។

៥. ហេតុនេះ អង្គជំនុំជម្រះយល់ឃើញថា លក្ខខណ្ឌតម្រូវនានានៅក្នុងវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ត្រូវបានបំពេញ និង សម្រេចទទួលយកឯកសារដែលបានស្នើសុំធ្វើជាឯកសារភ័ស្តុតាង ដោយដាក់លេខយោងជាឯកសារ E3/10649 ។